ទីស្តីការក្រសួងយុត្តិធម៌
លេខ ១៤៨៩ .កយអគ្គ/០៦

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីណែនាំ
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**សូមជម្រាបមក**

លោក លោកស្រី ប្រធានតុ អនុប្រធាន និងចៅក្រមគ្រប់តុលាការខេត្ត-ក្រុង

លោក លោកស្រី ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង អមតុលាការខេត្ត-ក្រុង

**កម្មវត្ថុ:** សេចក្តីណែនាំស្តីពីនីតិវិធីនៃការចោទប្រកាន់ និងការឃុំខ្លួនបណ្តោះអាសន្ន ក្នុងបទឆបោក និងរំលោភលើទំនុកចិត្ត ដែលមានពាក់ព័ន្ធនឹងពាណិជ្ជករ ឬអ្នកវិនិយោគ ។

**យោង:** អនុសាសន៍របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានលើកឡើងនាសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅព្រឹកថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៦ ។

កន្លងមកក្រសួងយុត្តិធម៌បានពិនិត្យឃើញថា តុលាកា និងអយ្យការខេត្ត-ក្រុង មិនបានអនុវត្តនូវអំណាចក្នុងការចោទប្រកាន់ និងការឃុំខ្លួនបណ្តោះអាសន្នក្នុងបទឆបោក និងរំលោភលើទំនុកចិត្ត ឱ្យបានត្រឹមត្រូវតាមស្មារតីនៃរដ្ឋធម្មនុញ្ញ និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាឡើយ ។ ការអនុវត្តនូវអំណាចបែបនេះដោយមិនបានពិចារណាលើសញ្ញាណគតិយុត្តនៃបទល្មើសដែលត្រូវចោទប្រកាន់ និងភាពចាំបាច់នៃការឃុំខ្លួនបណ្តោះអាសន្នបានបង្កឱ្យមានភាពអវិជ្ជមានកើតឡើង ដែលធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំង ដល់កិត្យានុភាពរបស់ប្រព័ន្ធច្បាប់ និងតុលាការ និងរាជរដ្ឋាភិបាលកម្ពុជាលើវិស័យសេដ្ឋកិច្ច ជាពិសេសការបាត់បង់នូវជំនឿទុកចិត្តរបស់ពាណិជ្ជករ និងអ្នកវិនិយោគ ដែលជាតួអង្គដ៏សំខាន់ក្នុងការចូលរួមអភិវឌ្ឍន៍ សេដ្ឋកិច្ចជាតិ បង្កើតការងារ និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

ដើម្បីបង្កើនការជឿទុកចិត្ត និងសុវត្ថិភាពគតិយុត្តរបស់ពាណិជ្ជករ និងអ្នកវិនិយោគ ក៏ដូចជាការលើកកម្ពស់កិត្យានុភាពរបស់ប្រព័ន្ធច្បាប់និងតុលាការ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងយុត្តិធម៌ សូមធ្វើការណែនាំដល់តុលាការ ចៅក្រមស៊ើបអង្កេត និងអយ្យការអម តុលាការខេត្ត-ក្រុងដូចខាងក្រោម ៖

១-ព្រះរាជអាជ្ញាអមតុលាការតុការខេត្ត-ក្រុងទាំងអស់ ត្រូវរាយការណ៍ជាបន្ទាន់មករដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងករណីមានការចោទប្រកាន់ពីបទឆបោក និងរំលោភលើទំនុកចិត្ត ដែលមានពាក់ព័ន្ធនឹងពាណិជ្ជករ ឬអ្នកវិនិយោគ

២-ក្នុងបទឆបោក និងបទរំលោភលើទំនុកចិត្ត រាល់ការចាប់ខ្លួននិងការឃុំខ្លួនបណ្តោះអាសន្នដែលអនុវត្តលើពាណិជ្ជករ និងអ្នកវិនិយោគ ត្រូវពិគ្រោះយោបល់ជាចាំបាច់ជាមួយក្រសួងយុត្តិធម៌ក្នុងរឿងក្តីធំៗ ដែលមានផលប៉ះពាល់ដោយផ្ទាល់ដល់សកម្មភាពពាណិជ្ជកម្ម វិនិយោគ និងសេដ្ឋកិច្ចជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវស្នើពិគ្រោះយោបល់ជាមួយប្រមុខរាជរដ្ឋាភិបាលកម្ពុជា ។

ក្រសួងយុត្តិធម៌ នឹងចាត់វិធានការយ៉ាងតឹងរ៉ឹងតាមផ្លូវច្បាប់ ចំពោះការមិនអនុវត្តឱ្យបានត្រឹមត្រូវតាមបញ្ញត្តិច្បាប់ និងសេចក្តីណែនាំនេះ ។

ទទួលបានសេចក្តីណែនាំនេះ តុលាការ និងអយ្យការគ្រប់ខេត្ត-ក្រុង ត្រូវអនុវត្តឱ្យមានប្រសិទ្ធិភាពនូវសេចក្តីណែនាំនេះ ។

ភ្នំពេញ ថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៦

**រដ្ឋមន្ត្រី**

**ចម ប្រសិទ្ធ**

<u>ចម្លងជូន</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

-តុលាការកំពូល និងមហាអការអមតុលាការកំពូល

-សាលាឧទ្ធរណ៍ និងមហាអយ្យការ

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងពាណិជ្ជកម្ម

-ឯកសារ-កាលប្បវត្តិ